-កងអាកាសចរភូមិន្ទកម្ពុជា ខាងក្រោមម្ដុង ដាក់រូបស្លាបសត្វទ្រម្ដុង ពណ៌មាស

**មាត្រា ២ :** រាល់ការផលិតសក្តិខុសពីរូបភាពខាងលើ ដែលកំណត់ក្នុងមាត្រា ១ ត្រូវបានហាមឃាត់ ។ នាយទាហាន និងពលទាហាននៃកងយោធពលខេមរភូមិន្ទ ត្រូវប្រើប្រាស់ត្រឹមត្រូវតាមការកំណត់ ។

**មាត្រា ៣ :** រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

**មាត្រា ៤ :** ក្រឹត្យនេះចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
ព្រះហស្តលេខា
**នរោត្តម សីហនុ**

បង្គំទូលថ្វាយ និងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
**តៀ បាញ់ , ឌា ឈីវ៉ាត់**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *

## II - ឯកសារគណៈរដ្ឋមន្ត្រី

### ១_ អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ១៤ អនក្រ .បក**

**ស្តីពីការបញ្ជាចំណាយឥតគ្រោងទុកមានលក្ខណៈចាំបាច់**
**របស់ក្រសួងការពារជាតិ**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម ១២៩៦.៣៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- **យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល**

**សំរេច**

**មាត្រា ១ :** កំណត់អោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោះស្រាយថវិកាសំរាប់ចំណាយឧបត្ថម្ភកំលាំងខ្មែរក្រហម ផ្តាច់ខ្លួនដែលបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលដូចខាងក្រោម :

0ÁÁâp

ក–អនុញ្ញាតផ្តល់ថវិកាចំនួន ៩៤៨.៧៨០.០០០រៀល សំរាប់ទិញអង្ករ ១.២៥៥តោន ពីប្រទេសថៃ ដើម្បីផ្គត់ផ្គង់កំលាំងខ្មែរក្រហមផ្តាច់ខ្លួនដែលបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលរយៈពេល បីខែដោយគិតពីខែ ធ្នូ ឆ្នាំ ១៩៩៦ ដល់ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

ខ–អនុញ្ញាតផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ ប្រាក់អាហារ ប្រាក់ម្ហូប អោយដល់កំលាំងខ្មែរក្រហមផ្តាច់ខ្លួន ដែលបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល រយៈពេលបីខែ

ដោយគិតពីខែ ធ្នូ ឆ្នាំ ១៩៩៦ ដល់ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ទៅតាមរបបកំណត់របស់កងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសហរដ្ឋមន្ត្រី ក្រសួងការពារជាតិត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយបានសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្ថលេខា និងត្រា ហត្ថលេខា និងត្រា
**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *

## III - ការងារបណ្តាក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

**ប្រកាសលេខ ០១៨ ប្រក.សហវ.ពដ**

**ស្តីពីការបង្កើតក្រុមការងារ ដើម្បីដឹកនាំ**
**ការចាត់ចែងអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧**

* * *

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា